# មេរៀនទី ១១៥៖ ព្រះយេស៊ូវយាងដើរលើទឹក

## ម៉ាថាយ ១៤៖២២-៣៣

**មេរៀនសម្រាប់គ្រូ** ( *យូធូបលីង* )៖ https://youtu.be/Zu2sQ0qu6rU

**រឿងនៅក្នុងព្រះគម្ពីរសម្រាប់កុមារ៖** https://youtu.be/1yV8NMazeHk

**គោលបំណង៖** ព្រះយេស៊ូវតែងតែខ្វល់ពីយើងសូម្បីតែពេលយើងសង្ស័យក៏ដោយ។

**ខគម្ពីរចងចាំ៖ ម៉ាថាយ ១៤៖៣៣** *“ឯពួកអ្នកដែលនៅក្នុងទូក ក៏មកថ្វាយបង្គំទ្រង់ទូលថា ទ្រង់ប្រាកដជាព្រះរាជបុត្រានៃព្រះមែន។”*

**ចំរៀង** ( *យូធូបលីង* )៖

១. បើទ្រង់គង់ជាមួយ https://youtu.be/2CzIW4_ueg0

២. គឺជាការល្អ https://youtu.be/Z91SULEHfho

៣. ពេលខ្យល់ព្យុះបក់ខ្លាំង https://youtu.be/lI5A7jKQb2o

**១. អធិស្ឋាន**

**២. ចំរៀង** ( *រើសចំរៀងខាងលើ១បទហើយច្រៀងជាមួយសិស្ស* )

**៣. ល្បែងកំសាន្ត** **«ជំហានតាមម៉ោង»**




១. ឲ្យកុមារណាម្នាក់(អាចជាកុមារដែលមានមាឌធំជាងគេក៏បាន) ស្ម័គ្រ ចិត្តធ្វើជាព្រះយេស៊ូវ ហើយឈរ នៅចុងម្ខាងនៃថ្នាក់រៀន

២. កុមារដែលនៅសេសសល់ទាំងប៉ុន្មាន ត្រូវឈរនៅចុង ម្ខាងទៀតនៃថ្នាក់រៀន ហើយពួកគេអាច ផ្លាស់ទីបាន នៅពេល ដែលគ្រូនិយាយ លេខណាមួយនៃម៉ោង




ឧទាហរណ៍៖ ប្រសិនបើគ្រូនិយាយថា “ម៉ោង៣” នោះមានន័យថាពួកគេអាច ដើរបាន ៣ ជំហាន។ ប្រសិនបើគ្រូនិយាយថា “ម៉ោង៥” នោះកុមារអាចដើរ បាន៥ជំហាន។

៣. គោលបំណងនៃល្បែងនេះគឺដើម្បីចូលទៅជិតព្រះយេស៊ូវហើយប៉ះទ្រង់បាន។

៤. កុមារទី១ដែលអាចប៉ះព្រះយេស៊ូវបានមុនគេកុមារនោះជាអ្នកឈ្នះល្បែងនេះ។ ប៉ុន្តែយើងនឹងបន្តលេងល្បែងនេះ រហូតដល់កុមារគ្រប់គ្នាៗបានប៉ះព្រះយេស៊ូវ។

៥. បន្ទាប់ពីលេងល្បែងនេះចប់សូមពន្យល់កុមារថា ព្រះយេស៊ូវស្រលាញ់យើងទោះបីជាយើងមានការសង្ស័យក៏ដោយ។

**៤. ការណែនាំមេរៀន**

តើការសង្ស័យមានន័យដូចម្តេច? វាគឺមានន័យថា ការដែលមិនច្បាស់ទៅលើអ្វីមួយ។ ប្រហែលជាអ្នកមាន ការសង្ស័យទៅលើមិត្តភក្តិរបស់អ្នកថាគេនឹងរក្សាការសន្យាឬអត់។ ឬក៏អ្នកមានការសង្ស័យចំពោះខ្លួនអ្នក ថាអាចរក្សាការសន្យាជាមួយឪពុកម្តាយរបស់អ្នកបានឬអត់។ វាគឺមានន័យថាអ្នកមិនប្រាកដអំពី

រឿងនោះ។ ថ្ងៃនេះយើងនឹងរៀនពីបុរសម្នាក់ ដែលបានធ្វើនូវរឿងដ៏អស្ចារ្យនៅពេលដែលគាត់គ្មាន ការសង្ស័យ ប៉ុន្តែគាត់ធ្វើដោយជំនឿ។

## ៥. រឿងនៅក្នុងព្រះគម្ពីរ

ថ្ងៃមួយព្រះយេស៊ូវបានបង្គាប់ឲ្យពួកសិស្សចុះទូក ហើយជិះឆ្លងទៅត្រើយម្ខាងនៃសមុទ្រកាលីឡេមុនទ្រង់ ព្រោះទ្រង់គង់នៅទីនោះនិងកំពុងអធិស្ឋាន។ នៅពេលដែលសិស្សទាំងអស់នៅលើទូកនោះ ក៏មានព្យុះមកដល់! ពួកសិស្សមានការភ័យខ្លាចជាខ្លាំង។ ព្រះយេស៊ូវបានចំណាយពេលអធិស្ឋានយ៉ាងយូរ ពីព្រោះព្រះគម្ពីរបាននិយាយថា ទ្រង់បានយាងទៅជួបពួកសិស្ស "នៅមុនពេលព្រឹកព្រលឹម។"

ប៉ុន្តែពួកសិស្សគឺនៅកណ្តាលសមុទ្រ ដូច្នេះតើព្រះយេស៊ូវអាចទៅរកពួកសិស្សបានដោយរបៀបណា? ព្រះគម្ពីរបាននិយាយថា ព្រះយេស៊ូវបានដើរលើទឹកដើម្បីទៅឯពួកគេ។ ពួកសិស្សមានការភ័យ ខ្លាចនៅពេលដែលពួកគេបានឃើញព្រះយេស៊ូវឈរនៅលើទឹក ព្រោះពួកគេគិតថា ទ្រង់គឺជាខ្មោច! នៅពេលដែលព្រះយេស៊ូវប្រាប់ថាគឺជាទ្រង់ ពេត្រុសបាននិយាយថា ប្រសិនបើជាព្រះយេស៊ូវមែនសូមជួយខ្ញុំអាចដើរនៅលើទឹកផង។

ដូច្នេះព្រះយេស៊ូវបានប្រាប់ពេត្រុសឲ្យមក ហើយពេត្រុសក៏ដើរនៅលើទឹកបាន! តើវាពិតជាអស្ចារ្យណាស់ឬ? នៅពេលដែលពេត្រុសផ្តោតទៅលើព្រះយេស៊ូវ គាត់ក៏អាចដើរនៅលើទឹកបានដែរ។ ប៉ុន្តែនៅពេលដែលគាត់បានឃើញព្យុះនិងរលកសមុទ្រ គាត់មានការសង្ស័យ។ គាត់ក៏ចាប់ផ្តើមមិនច្បាស់ក្នុងចិត្តថាតើគាត់គួរបន្តដើរទៀតឬអត់។ នោះហើយជាពេលដែលគាត់ចាប់ផ្តើមលិចចូលទៅក្នុងទឹក។ ព្រះយេស៊ូវក៏ប្រញាប់សង្គ្រោះគាត់ និងបានសួរគាត់ថា "ហេតុអ្វីបានជាអ្នកមានការសង្ស័យ?" ពេត្រុសមានការសង្ស័យនៅពេលដែលគាត់ឈប់មើលទៅឯព្រះ ហើយផ្តោតទៅលើលោកីយ៍វិញម្តង។

យើងអាចជឿទុកចិត្តលើព្រះយេស៊ូវ ហើយយើងក៏អាចមានចិត្តសង្ស័យនឹងទ្រង់ក្នុងពេលតែមួយផងដែរ។ សូម្បីតែមនុស្សចាស់ក៏នៅតែមានការសង្ស័យចុះទម្រាំយើងដែលជាក្មេង។ យើងមិនចាំបាច់មានអារម្មណ៍ថា ធ្វើខុសនោះទេ នៅពេលដែលយើងសង្ស័យទៅលើព្រះ ឬ ពីអ្វីដែលទ្រង់អាចធ្វើបាន ឬអត់នោះ។ អ្នកគ្រាន់តែមានចិត្ត ស្មោះត្រង់ជាមួយទ្រង់ប្រាប់ទ្រង់ពីអ្វីដែលអ្នកសង្ស័យ និងភ័យខ្លាច។ ព្រះទ្រង់នឹងយល់។

ការសង្ស័យរបស់ពួកយើងនឹងមានពេលមកនិងពេលទៅ ប៉ុន្តែវាមិនអាចផ្លាស់ប្តូរថា នរណាជាព្រះពិតប្រាកដបានទេ។ ពួកយើងប្រៀបបានដូចជាធូលីដី ដែលម្តងបក់ទៅទីនេះ ឬនៅទីនោះ។ ប៉ុន្តែព្រះគឺប្រៀបបាននឹងថ្ម ដែលរឹងមាំនិងច្បាស់លាស់។ អ្នកមិនអាចផ្លាស់ប្រែទ្រង់បានទេ ហើយអ្នកក៏មិនអាចផ្លុំទ្រង់ឲ្យទៅឆ្ងាយបានដែរ។ នៅពេលដែលពេត្រុសមានការសង្ស័យ ទ្រង់បានមកដល់នឹងសង្គ្រោះគាត់។ ព្រះតែងតែយកចិត្តទុកដាក់ និងឈរយ៉ាងរឹងមាំ បើទោះបីជាយើងមានការសង្ស័យក៏ដោយ ដូច្នេះនៅទីបំផុតយើងក៏អាចឈរមាំបាន។

## ៦. សំនួរពិភាក្សា

១. តើព្រះយេស៊ូវកំពុងធ្វើអ្វីនៅពេលដែលពួកសិស្សជិះទូកចេញទៅ? *(ព្រះយេស៊ូវកំពុងតែអធិស្ឋាន)*

២. តើព្រះយេស៊ូវទៅរកពួកសិស្សដោយរបៀបណា? *(ទ្រង់ដើរលើទឹក)*

៣. តើនរណាដែលបានសុំព្រះយេស៊ូវឲ្យគាត់អាចដើរលើទឹកដែរនោះ? *(ពេត្រុស)*

៤. ហេតុអ្វីបាជាគាត់លិចចូលទៅក្នុងទឹកនៅពេលដែលគាត់កំពុងដើរនោះ?
*(គាត់ឈប់ផ្តោតលើព្រះយេស៊ូវ និងមានការសង្ស័យនៅពេលដែលគាត់ឃើញខ្យល់ និងរលក)*

៥. តើអ្នកត្រូវធ្វើដូចម្ដេចនៅពេលដែលអ្នកមានការសង្ស័យចំពោះព្រះ? *(ប្រាប់ទ្រង់តាមត្រង់ ពីព្រោះព្រះតែងតែយល់ពីយើង និងនៅតែស្រលាញ់យើង មិនថាពេលដែលអ្នកមានការសង្ស័យក៏ដោយ)*

### ៧. ល្បែងកំសាន្ត «ជិះទូក»




១. ឲ្យកុមារគ្រប់គ្នាឈរនៅកណ្ដាលថ្នាក់រៀន

២. កុមារត្រូវរត់រកគ្នាតាមចំនួន លេខដែលគ្រូហៅ។ ឧទាហរណ៍៖ នៅពេលដែលគ្រូនិយាយថា "ជិះទូក២នាក់" កុមារត្រូវរកដៃគូរពីរៗនាក់ហើយឈរកាន់ដៃគ្នា។ ប្រសិនបើគ្រូ និយាយថា "ជិះទូកគ្នា ៧នាក់" នោះកុមារត្រូវរត់រកគ្នាឲ្យបាន៧នាក់ហើយឈរជាមួយគ្នា។

៣. ប្រសិនបើកុមារមិនអាចស្វែករកដៃគូរឲ្យបានដូចលេខដែលគ្រូ ដែលគ្រូនិយាយទេនោះ នោះពួកគេនឹងចាញ់ល្បែងនេះ។

៤. បន្តលេងល្បែងនេះរហូតនៅសល់កុមារតែ២នាក់ នោះពួកគេជាអ្នកឈ្នះល្បែងនេះ។

៥. បន្ទាប់ពីលេងល្បែងនេះចប់សូមពន្យល់កុមារថា ព្រះអង្គគង់នៅក្នុងទូកដែលពួកយើងកំពុងជិះ។ ព្រះនឹងដឹកនាំយើង ហើយជួយយើងឲ្យឆ្លងកាត់សមុទ្រនោះបាន។

### ៨. ខគម្ពីរចងចាំ

**ម៉ាថាយ ១៤៖៣៣** *"ឯពួកអ្នកដែលនៅក្នុងទូក ក៏មកថ្វាយបង្គំទ្រង់ទូលថា ទ្រង់ប្រាកដជាព្រះរាជបុត្រានៃព្រះមែន។"*

### ៩. ហត្ថកម្ម «ព្រះយេស៊ូវដើរលើទឹក»

សម្ភារៈដែលត្រូវការ៖ ព្រីនក្រដាសហត្ថកម្ម កូល័រ កន្ត្រៃ ដងឈើការ៉េម និងការបិត

១. ផាត់ពណ៌រូបព្រះយេស៊ូវ និងទូក

២. កាត់តាមបន្ទាត់រាងចតុកោណកែងជុំវិញទូក និងកាត់បន្ទាត់ខ្មៅជិតដែលនៅពីមុខទូក



៣. កាត់រូបព្រះយេស៊ូវ និងបិតដងឈើការ៉េមភ្ជាប់ជាមួយរូប ព្រះយេស៊ូវផ្នែកខាងក្រោយ

៤. ដាក់រូបព្រះយេស៊ូវកាត់តាមបន្ទាត់ជិត ខ្មៅដែលបានកាត់នៅពីមុខទូកនោះ ឥឡូវនេះព្រះយេស៊ូវអាចដើរលើទឹកទៅរកទូកបាន!

### ១០. ចំរៀង *(រើសចំរៀងខាងលើ១បទហើយច្រៀងជាមួយសិស្ស)*

### ១១. អធិស្ឋាន

**ការថ្វាយបង្គំសំរាប់គ្រូ៖ (សូមអាន ហើយអធិស្ឋានមុនពេលចាប់ផ្ដើមបង្រៀន)**
នៅពេលដែលអ្នកទុកចិត្តលើព្រះយេស៊ូវនោះអ្នកអាច "ដើរលើទឹកបាន។" ព្រះយេស៊ូវប្រទានឱ្យអ្នកនូវសមត្ថភាពដើម្បីសម្រេចនូវអ្វីដែលមិនអាចទៅរួច ដែលផ្ដល់ឱ្យទ្រង់នូវការយកចិត្តទុកដាក់ ដែលព្រះអង្គសមនឹងទទួលបាន។ សូមអានព្រះគម្ពីរ **ម៉ាថាយ ១៤៖២២-៣៣** សារឡើងវិញ។ តើអ្នកអាចមើលឃើញស្ថានភាពមួយណា ដែលធ្វើឲ្យអ្នកមានការភ័យខ្លាចដ៏លើសលប់នោះ? តើអ្នកអាចទុកចិត្តព្រះបានដោយរបៀបណាដើម្បីឲ្យអ្នកអាច "ដើរ" ឆ្លងកាត់ព្យុះដែលមានក្នុងជីវិតអ្នកបាន? ព្រះយេស៊ូវនឹងឆ្លើយតបជាមួយអ្នកដោយការស្រលាញ់និងការគាំទ្រ ដូចជាអ្វីដែលទ្រង់បានផ្ដល់ឲ្យពេត្រុសអីចឹងដែរ។ ព្រះអង្គចង់ផ្ដល់ឲ្យកូនរបស់ទ្រង់ទាំងអស់មានការលូតលាស់ខាងឯសេចក្ដីជំនឿ។

# ព្រះយេស៊ូវយាងដើរលើទឹក







១. ផាត់ពណ៌រូបព្រះយេស៊ូវ និងទូក

២. កាត់តាមបន្ទាត់រាងចតុកោណកែងជុំវិញទូក និងកាត់បន្ទាត់ ខ្មៅដិតដែលនៅពីមុខទូក

៣. កាត់រូបព្រះយេស៊ូវ និងបិតដងឈើការ៉េមភ្ជាប់ជាមួយរូប ព្រះយេស៊ូវ ផ្នែកខាងក្រោយ

៤. ដាក់រូបព្រះយេស៊ូវកាត់តាមបន្ទាត់ដិត ខ្មៅដែលបានកាត់នៅពី មុខទូកនោះ

ឥឡូវនេះព្រះយេស៊ូវអាចដើរលើទឹកទៅរកទូកបាន!